# គោលនយោបាយស្តីពីការប្រឆាំងការសម្អាតប្រាក់ និងការស្គាល់អតិថិជន

## (សង្ខេប)

អនុលោមតាមគោលនយោបាយរបស់ក្រុមហ៊ុន កូម៉ូ ធី ឯ.ក និងដៃគូពាក់ព័ន្ធ (តទៅហៅថា COMMO T) បានហាមឃាត់យ៉ាងតឹងរឹងបំផុត និងចាត់វិធានការជាបន្តបន្ទាប់ដើម្បីការពារ និងប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ និងរាល់សកម្មភាពដែលសម្របសម្រួលដល់ការសម្អាតប្រាក់ និងប្រយុទ្ធប្រឆាំងនឹងការផ្តល់ហិរញ្ញប្បទានភេរវកម្ម។ គោលនយោបាយនេះ បានដាក់ចេញនូវបទដ្ឋានជាមូលដ្ឋានសម្រាប់ការកំណត់អត្តសញ្ញាណរបស់អតិថិជន ដើម្បីការពារការប្រើប្រាស់ផលិតផល និងសេវាកម្មរបស់ COMMO T សម្រាប់ជាគោលបំណងក្នុងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ COMMO T ត្រូវឱ្យនិយោជិត និងដៃគូពាក់ព័ន្ធទាំងអស់គោរពតាមបទដ្ឋានទាំងអស់នេះ ដើម្បីការពារការប្រើប្រាស់ផលិតផល និងសេវាកម្មរបស់ COMMO T សម្រាប់ជាគោលបំណងក្នុងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ក៏ដូចជាការប្រើប្រាស់ដោយខុសច្បាប់សម្រាប់ការសម្អាតប្រាក់ ការផ្តល់ហិរញ្ញប្បទានភេរវកម្ម ឬបទល្មើសហិរញ្ញវត្ថុដទៃទៀត។

សម្រាប់គោលបំណងនៃគោលនយោបាយនេះ និងដោយអនុលោមតាមច្បាប់ស្តីពីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម នៃព្រះរាជាណាចក្រកម្ពុជា **ការសម្អាតប្រាក់** សំដៅដល់ (i) ការបំប្លែង ឬការផ្ទេរទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិនេះជាផលនៃបទល្មើសក្នុងគោលបំណងបិទបាំង ឬក្លែងប្រភពដើមមិនស្របច្បាប់នៃទ្រព្យសម្បត្តិទាំងនេះ ឬជួយបុគ្គលណាដែលបានពាក់ព័ន្ធក្នុងបទល្មើស ដើម្បីឱ្យបុគ្គលនោះគេចផុតពីផលវិបាកតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួន។ (ii) ការបិទបាំង ឬការក្លែងភាវៈពិត ប្រភព ទីតាំង សិទ្ធិចាត់ចែង ចលនា ឬកម្មសិទ្ធិ ឬសិទ្ធិលើទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិទាំងនេះបានមកពីបទល្មើស។ (iii) ការធ្វើលទ្ធកម្ម ការកាន់កាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិទាំងនេះបានមកពីបទល្មើស។ (iv) ការចូលរួម ការប៉ុនប៉ងប្រព្រឹត្ត ដោយជួយ និងជំរុញឱ្យប្រព្រឹត្តសកម្មភាពណាមួយដែលបានកំណត់។ ដោយឡែក **ហិរញ្ញប្បទានភេរវកម្ម** សំដៅដល់ការផ្តល់ ឬការប្រមូលដោយចេតនានូវទ្រព្យសម្បត្តិ មូលនិធិ ឬសេវាផ្សេងៗក្នុងគោលបំណងប្រើប្រាស់ ឬដោយដឹងថាទ្រព្យសម្បត្តិ មូលនិធិ ឬសេវានេះនឹងត្រូវបាន ឬអាចប្រើប្រាស់ទាំងមូល ឬមួយផ្នែកសម្រាប់គាំទ្ររាល់សកម្មភាព ជាអាទិ៍ ការធ្វើដំណើរការបណ្តុះបណ្តាល ការរៀបចំ ការចូលរួម ឬការប្រព្រឹត្តអំពើភេរវកម្ម របស់ភេរវករ ឬអង្គការចាត់តាំងរបស់ភេរវកម្ម។

និយោជិតថ្មីទាំងអស់នឹងទទួលបានការបណ្តុះបណ្តាលពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលវាជាផ្នែកមួយនៃការបណ្តុះបណ្តាលនិយោជិតដែលជ្រើរើសថ្មីរបស់ក្រុមហ៊ុន។ ស្របពេលជាមួយគ្នានេះដែរ និយោជិតផ្សេងទៀតក៏នឹងទទួលបាននូវការបណ្តុះបណ្តាលជាប្រចាំអំពីគោលនយោបាយស្តីពីការប្រឆាំងការសម្អាតប្រាក់ និងការស្គាល់អតិថិជនផងដែរ។ ដូចនេះ គ្រប់និយោជិតរបស់ COMMO T ទាំងអស់ សុទ្ធតែបានបណ្តុះបណ្តាល និងឆ្លងកាត់វគ្គបណ្តុះបណ្តាល អំពីគោលនយោបាយស្តីពីការប្រឆាំងការសម្អាតប្រាក់ និងការស្គាល់អតិថិជន។ ចំពោះនិយោជិតដែលមានកាតព្វកិច្ចទាក់ទងនឹងផលិតផល និងសេវាកម្មរបស់ COMMO T និងអ្នកដែលទាក់ទងផ្ទាល់ ឬដោយប្រយោលជាមួយអតិថិជនរបស់ COMMO T គឺរំពឹងថានឹងដឹងពីតម្រូវការដែលបានកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិដែលអាចប៉ះពាល់ដល់ការទទួលខុសត្រូវរបស់និយោជិតនោះ។ ហើយវាគឺជាកាតព្វកិច្ចរបស់និយោជិតក្នុងការបំពេញភារកិច្ចទាំងនោះគ្រប់ពេលវេលាដោយអនុលោមតាមការតម្រូវរបស់ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ។ ក្រៅពីនោះ ក្រុមការងារផ្នែកអនុវត្តច្បាប់របស់ COMMO T នឹងអង្កេត និងតាមដានលើការអនុវត្តដើម្បីធានាឱ្យបាននូវការអនុវត្តគោលនយោបាយស្តីពីការប្រឆាំងការសម្អាតប្រាក់ និងការស្គាល់អតិថិជនមានប្រសិទ្ធិភាពខ្ពស់។ វាគឺជាការទទួលខុសត្រូវក្នុងការត្រួតពិនិត្យលើគ្រប់ផ្នែកទាំងអស់នៃការប្រឆាំងការសម្អាតប្រាក់ និងប្រយុទ្ធប្រឆាំងនឹងហិរញ្ញប្បទានភេរវកម្មរបស់ COMMO T។ ដៃគូសហការ និងសមាជិករបស់ COMMO T ទាំងអស់នឹងតម្រូវឱ្យគោរពតាមគោលនយោបាយស្តីពីការប្រឆាំងការសម្អាតប្រាក់ និងការស្គាល់អតិថិជន។

+(855)86 988 900
commot.asia
info@commot.asia
#42, St.214(Somdach Pan), Sayon Phnom Penh, Phnom Penh, Cambodia

រាល់ការកត់ត្រាពីព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជន និងទិន្នន័យនៃការធ្វើប្រតិបត្តិការរបស់អតិថិជន ត្រូវរក្សាទុកយ៉ាងហោចណាស់ ត្រឹមរយៈពេលអប្បបរមាដែលបានកំណត់ដោយច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម នៃព្រះរាជាណាចក្រកម្ពុជា គិតចាប់ពីពេលដែលគណនីរបស់អតិថិជននោះបានបិទ ឬទំនាក់ទំនងពាណិជ្ជកម្មរវាងក្រុមហ៊ុន និងអតិថិជននោះបានបញ្ចប់។

សម្រាប់ព័ត៌មានបន្ថែមអំពីគោលនយោបាយស្តីពីការប្រឆាំងការសម្អាតប្រាក់ និងការស្គាល់អតិថិជន សូមយោងទៅលើឯកសារផ្លូវការនៃគោលនយោបាយស្តីពីការប្រឆាំងការសម្អាតប្រាក់ និងការស្គាល់អតិថិជន ឬធ្វើការទំនាក់ទំនងមកកាន់យើងខ្ញុំតាមរយៈសារអេឡិចត្រូនិច info@commot.asia ៕